101/13

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

756
18-8-2014

**សាលាដំបូង រាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌ
លេខ ២៨៩៦
ចុះថ្ងៃទី ២២-៩-២០១៣
សាលក្រមព្រហ្មទណ្ឌ
លេខ ៥០កបប២"ឆ"
ចុះថ្ងៃទី ២៨-៥-២០១៤

## គាននាមប្រជារាស្ត្រខ្មែរ

សាលាដំបូងរាជធានីភ្នំពេញ បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤ វេលាម៉ោង ៨និង ០០នាទីព្រឹក ដោយមានសមាសភាពចូលរួមដូចតទៅ:

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ចៅក្រមប្រឹក្សា
លោកស្រី [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៨៩៦ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៣ ដែលមានៈ

១-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ២៣ឆ្នាំ ជាតិនីហ្សេរីយ៉ា (NIGERIAN) មុខរបរ រកស៊ី កើតនៅ ប្រទេសនីហ្សេរីយ៉ា ទីលំនៅមុនពេលឃាត់ខ្លួននៅ ផ្ទះជួលលេខ១៧B ផ្លូវ៥១០ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ SAMUEL UCHE MAX "រស់" ម្តាយឈ្មោះ OPOLONIA NWOKO "រស់" នៅលីវ ជានីតិជន ទោសពីមុន គ្មាន (ក្នុងឃុំ)។

ចាប់ខ្លួនថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួន លេខ ១៥៥៧តព្រ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣។

២-ជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ៥១ឆ្នាំ ជាតិអូស្ត្រាលី មុខរបរ គ្រូបង្រៀន កើតនៅ ប្រទេសអូស្ត្រាលី ទីលំនៅមុនពេលឃាត់ខ្លួននៅ ផ្ទះលេខ៣៣ ផ្លូវBuckingham ក្រុង Mt Hallen Queensland Australia ឪពុកឈ្មោះ BARRY TAYLOR "រស់" ម្តាយឈ្មោះ MARLENE WILSON "រស់" ប្តីឈ្មោះ HARLEY YOUNG ជានីតិជន ទោសពីមុន គ្មាន (ក្នុងឃុំ)។

ចាប់ខ្លួនថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួន លេខ ១៥៥៦តព្រ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣។

៣-ជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ១៩ឆ្នាំ ជាតិបារាំង មុខរបរ ធ្វើការនៅភោជនីយដ្ឋាន Le Duo កើតនៅ ប្រទេសបារាំង ទីលំនៅមុនពេលឃាត់ខ្លួននៅ ផ្ទះលេខ១៤ ផ្លូវលេខ៥៩ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ LUIGI SAVARINO "ស្លាប់" ម្តាយឈ្មោះ SYLVIE ROUSSELLE "រស់" នៅលីវ ជានីតិជន ទោសពីមុន គ្មាន (ក្នុងឃុំ)។

ចាប់ខ្លួនថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួន លេខ ១៥៥៥តព្រ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣។

៤-ជនជាប់ចោទឈ្មោះ [redacted] ហៅ NTO ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិនីហ្សេរីយ៉ា កើតនៅ ONITSHA ប្រទេសនីហ្សេរីយ៉ា ទីលំនៅ ផ្ទះលេខ១A ផ្លូវលេខ៤៥BT ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាន់លិខិតឆ្លងដែនលេខ A0៤៦៥៧២០៩ ([redacted])។

៥-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស ជាតិនីហ្សេរីយ៉ា កើតនៅ ក្រុងបេនីន ប្រទេសនីហ្សេរីយ៉ា (Benin City, Nigeria) កាន់លិខិតឆ្លងដែនលេខ A០១១៧០៩៥២ (គេចខ្លួន)។

ត្រូវចោទពីបទ ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន (ឆ្លងដែន) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ជនជាប់ចោទឈ្មោះ [redacted] មានលោក [redacted] ជាមេធាវីការពារសិទ្ធិ និងលោក ប៊ុត ប៊ិណារ៉ែត ជាអ្នកបកប្រែ។

✓-ជនជាប់ចោទឈ្មោះ T[redacted]NN មានលោក [redacted] ជាមេធាវីការពារសិទ្ធិ និងលោក ឡេង សុវណ្ណារិទ្ធ ជាអ្នកបកប្រែ។

✓-ជនជាប់ចោទឈ្មោះ [redacted] មា[redacted]លោក [redacted]

-ជនជាប់ចោទឈ្មោះ [redacted] ហៅ NTO និងឈ្មោះ ASEMOTA JUSTICE OSAHENI មានលោក [redacted] មេធាវីការពារសិទ្ធិ។

## អង្គហេតុនៃរឿងមានដូចតទៅ

នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣ សមត្ថកិច្ចប្រទេសអូស្ត្រាលីបានធ្វើការចាប់ខ្លួនជនជាតិអូស្ត្រាលីឈ្មោះ [redacted] ភេទប្រុស អាយុ ៥៤ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ ៥២ឆ្នាំ នៅប្រទេសអូស្ត្រាលី ដកហូតបានម្សៅហេរ៉ូអ៊ីន ចំនួន ០៨(ប្រាំបីគីឡូក្រាម) ដែលជនល្មើសទាំងពីរបានទទួលពីជនត្រូវចោទឈ្មោះ [redacted] ពីប្រទេសកម្ពុជា។ បន្ទាប់មកសមត្ថកិច្ចប្រទេសអូស្ត្រាលីបានផ្តល់ព័ត៌មានមកនាយកដ្ឋានភេរវកម្មក្រសួងមហាផ្ទៃ។ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ឈ្មោះ [redacted] ហៅ NTO បានយកកាបូបស្ពាយមួយឱ្យជនត្រូវចោទឈ្មោះ [redacted] នៅផ្ទះជួលលេខ១៧B ផ្លូវ៥១០ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ដើម្បីប្រគល់ឱ្យទៅឈ្មោះ JOHN ភេទប្រុស សញ្ជាតិអូស្ត្រាលី នៅ Brisbane ប្រទេសអូស្ត្រាលី។ នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ វេលាម៉ោង១១និង៣០នាទីព្រឹក ឈ្មោះ [redacted] បានប្រគល់កាបូបស្ពាយខាងលើឱ្យទៅឈ្មោះ [redacted] ប្រគល់បន្តឱ្យទៅជនត្រូវចោទឈ្មោះ [redacted] យកទៅប្រទេសអូស្ត្រាលីតាមច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ ពេលដែលជនត្រូវចោទឈ្មោះ [redacted] និង [redacted] យកកាបូបចូលដល់ក្នុងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ក៏ត្រូវសមត្ថកិច្ចធ្វើការចាប់ខ្លួនអ្នកទាំងពីរព្រមទាំងឆែកឆេរកាបូបស្ពាយខាងលើរកឃើញម្សៅហេរ៉ូអ៊ីនទម្ងន់ ២០០២,៤០(ពីរពាន់ពីរក្រាមសែសិប)ក្រាម និងបន្តចាប់ខ្លួនជនត្រូវចោទឈ្មោះ [redacted] ល:ក្រោយពីបានស៊ើបអង្កេតរបស់ចៅក្រមស៊ើបសួររួចមកបានរកឃើញឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស ជនជាតិនីហ្សេរីយ៉ា មានជាប់ពាក់ព័ន្ធក្នុងការទទួលគ្រឿងញៀន និងផ្ញើលុយឱ្យឈ្មោះ [redacted]។

-របាយការណ៍ លេខ ១៣១ សណ/១៣ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៣ របស់ការិយាល័យប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន។

-ដីកាសន្និដ្ឋានស្ថាពរលេខ ២០៤ អ.យ.ង ចុះថ្ងៃ០៣ ខែកុម្ភៈ ឆ្នាំ២០១៤ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥២៤ ដ.ជ.រ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## **នរពេលសមនាការ**

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថាៈ ខ្លួនទទួលស្គាល់ចម្លើយនៅសមត្ថកិច្ច នៅអយ្យការ និងនៅតុលាការ។ ខ្លួនស្គាល់ឈ្មោះ Taylor និង Savarino។ Savarino ជាមិត្តស្រីខ្លួន។ ខ្លួនស្គាល់ឈ្មោះ David និង Cathryn ជនជាតិអូស្ត្រាលីទាំងពីរនាក់ តែអត់ដឹងគាត់ធ្វើអ្វីទេ គ្រាន់តែជួយនាំទំនិញ (Laptop, សំលៀកបំពាក់, ទូរទស្សន៍, ទូរស័ព្ទ) របស់ខ្លួនចេញចូល ខ្លួនអត់ដឹងថាគេចាប់គាត់ទេ។ ចំពោះកាបូបដែលថា Savarino និង Taylor ទទួលពីខ្លួន ការពិតត្រូវយកទៅឱ្យ Cathryn ខ្លួនបានមកពី NTO ជាតិនីហ្សេរីយ៉ា ដែលជាអ្នកជួយការងារខ្លួនដែរ គាត់ឱ្យខ្លួនដើម្បីឱ្យវត្ថុសិល្បៈទៅអតិថិជនគាត់។ ខ្លួនបានបើកមើលឃើញសម្ភារៈសិល្បៈខ្លួនយកពី NTO បាន០៣ដង និង០៣ដងយកខ្លួនឯង។ ខ្លួនអត់បានលុយពី NTO ទេតែតាមពិតខ្លួនត្រូវបាន ៣០០០$។ ឃាត់ខ្លួននៅបន្ទប់ទទួលភ្ញៀវ ក្នុងផ្ទះនៅផ្សារដើមគរ។ កាបូបមិនមែនកាបូបនៅសវនាការនេះទេ កាបូបនោះគឺពណ៌ខ្មៅ តូចជាងនេះដែលដាក់វត្ថុសិល្បៈ ខ្លួនអត់ដឹងថាមានកាបូបនេះទេ នៅថ្ងៃឃាត់ខ្លួនសមត្ថកិច្ចអត់បានបង្ហាញកាបូបទេ ក្រោយមកទើបបង្ហាញនៅតុលាការ។ កាបូបផ្ញើទៅអូស្ត្រាលី ០៥ដងហើយនេះជាលើកទី៦។ កាបូបខ្លួនអត់បានទិញទេ។ ខ្លួននៅកម្ពុជា០៨ឆ្នាំ ធ្វើការនាំចេញនាំចូលទើបតែធ្វើពីមុនខ្លួនទិញវត្ថុបុរាណលក់ដូរនៅស្រុកខ្មែរ មានដូចជាត្បូង។ ការផ្ញើកាបូបចេញដំបូងគឺខែកក្កដា ឆ្នាំមុន ជូនកាល០១ខែផ្ញើម្តង។ ធម្មតាខ្លួនទិញរបស់ពីផ្សារផ្ញើទៅខ្លួនឯង លើកនេះផ្ញើតាមគេដោយសារខ្លួនជាប់រវល់ ហើយថ្ងៃនោះនាង(Savarino)មក ខ្លួននៅគេង ខ្លួនផ្ញើតាមមិត្តស្រីបាន០៣ដង។ កាបូបដែល NTO យកមកផ្ញើមាន០៤ គាត់យកមកឱ្យខ្លួននៅផ្ទះ ពីមុនខ្លួនមើលឱ្យដឹងថាជាវត្ថុសិល្បៈ លើកនេះខ្លួនឆែកកាបូបហើយទុកនៅលើសាឡុង ខ្លួនស្គាល់កាបូបអត់មានសង្ស័យអ្វីទេ អត់បានយកឱ្យ Taylor ទេគឺ Savarino ជាអ្នកប្រគល់ឱ្យ Taylor។ ពេលដែលសមត្ថកិច្ចឃាត់ខ្លួនមានជនជាតិកាណាដាម្នាក់ទៀត។ ការយកកាបូបគឺ Savarino ជាអ្នកយកទៅពេលព្រឹកទៅឱ្យ Taylor នៅសណ្ឋាគារ មុនទៅព្រលានខ្លួនមិនបានទៅជួបនាង(Taylor)ទេ។ ខ្លួនស្គាល់ Taylor តាមរយៈ Internet ចាប់ពីខែ៣-៤ គាត់មកកម្ពុជាដោយខ្លួនជាអ្នកហៅមកក្នុងលិខិតខ្លួនបានសុំឱ្យគាត់បើកហាងលក់វត្ថុអនុស្សាវរីយ៍នៅអូស្ត្រាលី អស់ប្រាក់ ៥០០០០$ សំរាប់ឈ្នួលកន្លែងចំនួន ០៧ខែ ជួលក្នុង០១ខែ ២០០០$-៣០០០$។ លុយ ៥០០០០$ ពុំទាន់បានឱ្យទេ អត់មានឱ្យអ្វីផ្សេងទេ។ Taylor មកដំបូងបានជួយយកឥវ៉ាន់ពីអូស្ត្រាលីមកខ្មែរ ជំនួសខ្លួន ពេលមកដល់កម្ពុជាខ្លួនបាននាំគាត់ទៅដើរលេងនៅកែប។ លើកនេះគាត់មកខ្លួនមិនបានទៅទទួលទេព្រោះស្រវឹង ហើយ NTO បានប្រាប់ Savarino ឱ្យទៅទទួល Taylor។ កាបូប NTO ឱ្យទុកឱ្យ Taylor នៅថ្ងៃទី១៨ ខ្លួនអត់បានយកទៅបែរជា Savarino យកទៅឱ្យ ព្រោះខ្លួនត្រូវទៅធ្វើសក់នៅចោមចៅ តាមពិតគឺខ្លួនជាអ្នកដែលត្រូវជូន Taylor ទៅ។ ពេល Savarino និង Taylor ទៅដល់ព្រលានយន្តហោះ ខ្លួនបានផ្ញើលេខ John ទៅ Savarino ហើយបានប្រាប់នាងឱ្យប្រាប់ Taylor ថាទាក់ទងទៅ John នៅអូស្ត្រាលី។ ពេលខ្លួនឱ្យ Savarino យកកាបូបទៅខ្លួនអត់បានផ្តាំវីនិយាយអ្វីទេ គ្រង់ខ្លួនប្រាប់ Savarino ឱ្យប្រាប់ Taylor ឱ្យយកកាបូបជាប់ខ្លួនកុំទុកនៅកាប៊ីន៕

ជាសំដី NTO ផ្តាំខ្លួនក៏ប្រាប់ Savarino បន្ត ហេតុដែលខ្លួនស្តាប់សំដី NTO ដោយសារទំនិញត្រូវបញ្ចូនឱ្យអតិថិជនគាត់។ លុយបើកហាងមានចំណែកប្រាក់ខែ Taylor ដែរ ហើយកិច្ចសន្យាធ្វើនៅពេលគាត់មកលើកទី២។ កាបូបនោះគឺ NTO ជាអ្នកទិញមកឱ្យខ្លួន សំរាប់ដាក់វត្ថុសិល្បៈទុកផ្ញើទៅអូស្ត្រាលី ការទិញកាបូបខ្លួនអត់បានកម្ម៉ង់គាត់ទេ គឺ NTO យកមកថ្ងៃទី១៦ ខ្លួនមិនបានរំពឹងថាគាត់ទិញមកទេ ហើយគាត់អត់បានប្រាប់ថានឹងយកកាបូបនេះវិញទេ។ កាបូបយកមកអត់មានអ្វីទេ ហើយខ្លួនជូនគាត់ទៅផ្សារដើរទិញឥវ៉ាន់ដាក់ចូលសម្រាប់អតិថិជនគាត់ទិញសំលៀកបំពាក់ប្រពៃណី ក្រណាត់ រួចយកមកទុកនៅផ្ទះវិញ។ ពេលយកកាបូបទៅខ្លួនមិនបានឱ្យលុយ Savarino ទេ ខ្លួនធ្លាប់ប្រាប់នាងថាខ្លួនរៀនចប់សាលាពេទ្យ ឪពុកជាមន្ត្រីរាជរដ្ឋាភិបាល ម្តាយអ្នកលក់សាំង ហើយពួកខ្លួននៅផ្ទះបែកគ្នា។ ខ្លួនចំណាំកាបូបមិនច្បាស់ទេ ព្រោះពេលយកមកខ្លួនបើកមើលហើយទុកនៅកៀន ពេលទៅទិញឥវ៉ាន់មិនបានយកទៅទេ មកវិញដាក់ឥវ៉ាន់ហើយទុកចោល ដល់ថ្ងៃទើបឱ្យ Savarino យកទៅខ្លួនអត់ចាប់អារម្មណ៍ទេ។ ចំពោះ Taylor ខ្លួនមិនបានឱ្យលុយគាត់ទេ។ ខ្លួនមកខ្មែរជាង០៤ឆ្នាំ ចេញចូល០៥ដង ខ្លួនមកដោយមានកូនប្រុសមិត្តភក្តិឪពុកខ្លួននៅកម្ពុជាខ្លួនមកលេង និងដើម្បីបញ្ចប់ការសិក្សា គឺធ្វើកម្មសិក្សានៅពេទ្យរុស្ស៊ី ការនាំចេញនាំចូលឥវ៉ាន់គឺខ្លួនធ្វើមែនចាប់ផ្តើមបន្ទាប់ពីមកខ្មែរបាន០៦ខែ ខ្លួនធ្វើការឱ្យក្រុមហ៊ុន Global Session International ជារបស់បងប្រុស។ ក្រោយមកខ្លួនរៀបនឹងបើកគឺ Precious Shipping Company។ ឥវ៉ាន់ខ្លួនបាននាំចេញនាំចូលទៅប្រទេសអូស្ត្រាលីដោយ Taylor ប្រាប់ថាទីផ្សារល្អ។ ខ្លួនមិនស្គាល់ឈ្មោះ ចាន់ ទេ។ Taylor មិនស្គាល់ NTO ទេ ហើយ NTO ក៏មិនដែលឱ្យថៃ្លផ្ញើឥវ៉ាន់រំលាយទេ។

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា: ខ្ញុំស្គាល់Precious ជាមិត្តភក្តិ ស្គាល់១១ខែ ខ្ញុំមកកម្ពុជា០៣ដង លើកទី១គាត់ហៅខ្ញុំមកដើម្បីវិស្សមកាល០៦ថ្ងៃ។ លើកទី២ គាត់ហៅមកដើម្បីផ្តល់ការងារឲ្យខ្ញុំធ្វើ (ការងារគ្រូបង្រៀននៅអូស្ត្រាលីខ្ញុំឈប់ធ្វើព្រោះហត់ពេក) ធ្វើការបើកហាងលក់វត្ថុសិល្បៈនៅអូស្ត្រាលី (គឺលោកចាន់បានបើកហាង) Precious ថានឹងឲ្យប្រាក់ខែមកខ្ញុំចំនួន $១៨០០ សំរាប់មួយសប្តាហ៍ តែខ្ញុំអត់ទាន់បានទទួលលុយទេ តែចុះកុងត្រាហើយជាកិច្ចសន្យាការងារ មករយៈពេល០៥ថ្ងៃ ខ្ញុំចេញពីកម្ពុជាគឺPreciousជូនដំណើរ ចំណាយរបស់ខ្ញុំគឺលោកចាន់ជាអ្នកចេញ លើកទី២ខ្ញុំយកឥវ៉ាន់ទៅមានវត្ថុបុរាណដែលដាក់ក្នុងកាបូប។ លើកទី៣ ខ្ញុំមកកម្ពុជាដោយសារខ្ញុំឈឺ អត់មានលុយខ្ញុំមកដើម្បីយកលុយ គឺPrecious ជាអ្នកហៅមកតែ Charleneជាអ្នកទទួលខ្ញុំជូនទៅសណ្ឋាគារក្រោយមក Precious មកដល់សណ្ឋាគារ។ ស្អែកឡើងខ្ញុំបានចុះកិច្ចសន្យាជាមួយCharlene ជួលផ្ទះ០៦ខែនិងសុំអាជ្ញាប័ណ្ណអស់ចំនួន$៥០,000(ប្រាំម៉ឺន)ដុល្លាអាមេរិក បើកហាងនៅអូស្ត្រាលីតែអត់ទាន់បានលុយទេ ចាកចេញវិញថ្ងៃទី១៨។ លើកទី៣ខ្ញុំជួប Charlene នាងជាបុគ្គលិករបស់លោកចាន់ដែរ នាងថាអត់ស្គាល់ឈ្មោះ Precious ទេ ថ្ងៃចេញដំណើរ Charlene ជាអ្នកឲ្យឥវ៉ាន់ឲ្យនៅសណ្ឋាគារជាកាបូបនេះ(នៅសរនាការ)មិនមែនជា Precious ហើយនាងជូនខ្ញុំទៅព្រលានយន្តហោះ នាងប្រាប់ថាបានកាបូបពី Precious ទៅព្រលានជិះតាក់ស៊ី ពេលទៅដល់អត់ចាំអ្នកណាកាន់ទេ គឺខ្ញុំជាអ្នកកាន់កាបូបចូលមែន Charlene ទៅបន្ទប់រងចាំ ខ្ញុំចូលឆែកPassport ពេលនោះសមត្ថកិច្ចឃាត់ខ្លួនខ្ញុំពេលនោះខ្ញុំក៏ប្រាប់សមត្ថកិច្ចក៏ចាប់ Charlene ដែរ។ ពេលCharlene យកកាបូបមកខ្ញុំបានបើកមើលកាបូបថត្សប់លើកឥវ៉ាន់ចេញមាន០៧ដុំ មាន០៣ដុំជាគ្រឿងចម្លាក់,០៤ដុំវត្ថុភ្លឺ។ ខ្ញុំអត់ឃើញមានគ្រឿងញៀនទេ សមត្ថកិច្ចឆែកវះកាបូបទើបឃើញមានម្សៅពណ៌ស។ ពេលប៉ូលីសចាប់ខ្ញុំសួរអ្នកណាឲ្យកាបូបខ្ញុំ ខ្ញុំថាCharleneទើបទៅចាប់នាង។ ពេលសមត្ថកិច្ចវះកាបូបខ្ញុំឃើញផ្ទាល់ភ្នែក Charlene មកដល់ពេលគេកំពុងពិនិត្យម្សៅនោះ។ ការចាប់ Precious ដោយប៉ូលីសសួរខ្ញុំនិង

Charlene ច្រើនសំណួរ។ ពេល Charlene យកកាបូបឲ្យនាងប្រាប់ថានាងធ្លាប់បាត់វ៉ាលីឲ្យទុកជាប់ខ្លួនកុំឲ្យបាត់ នាងពុំមានឲ្យលុយខ្ញុំទេក្នុងការផ្ញើ នាងប្រាប់ថាពេលទៅដល់អូស្ត្រាលីទាក់ទងគេ ពុំចាំឈ្មោះនិងមានលេខ។ ពេលខ្ញុំមកលើកទី២ Precious បានឲ្យខ្ញុំយកឥវ៉ាន់ទៅអូស្ត្រាលីដែរ ផ្ញើឲ្យគេផ្សេងគឺជាខ្មែរ(ប្រុស) ផ្ញើវត្ថុសិល្បៈ ខ្ញុំបាន $១០០០។ ពេលចាប់ខ្លួនប៉ូលីសពុំបាននាំទៅចាប់ Precious ទេ។ ខ្ញុំអត់ស្គាល់ឈ្មោះចាន់ទេ គាត់ជាខ្មែរ Precious ថាគាត់អត់ចេះអង់គ្លេស លុយគឺលោកចាន់ជាអ្នកចំណាយតាមរយៈ Precious លើកទី១, ទី២ និងទី៣ គឺ Precious ចំណាយឲ្យខ្ញុំ។ ខ្ញុំអត់ស្គាល់ឈ្មោះ NTO ទេ។ កាបូប Preciousជាអ្នកឲ្យយកឲ្យបានឆែកមើលទាំងអស់គ្នា ឃើញតែសំលៀកបំពាក់ ឆែកនៅកន្លែងlobby ពេលរសៀលពុំចាំម៉ោង នាងជួបខ្ញុំប្រហែល៣០នាទីទៅ០១ម៉ោងនិយាយគ្នាពាក់ព័ន្ធជំនួញនៅអូស្ត្រាលី នាងប្រាប់ថាកុំឲ្យបាត់កាបូប ខ្ញុំថតឥវ៉ាន់នៅសណ្ឋាគារនៅពេលរសៀល ពេលCharlene ចេញបាត់ទៅហើយថតនៅក្នុងបន្ទប់ ខ្ញុំអត់បានជួប Precious ទេ អត់បានផ្ញើឲ្យ Preciousទេ ថតដើម្បីឲ្យដឹងឥវ៉ាន់ត្រូវទទួលខុសត្រូវ ពេលនោះខ្ញុំចង់យកឥវ៉ាន់ដាក់នៅលើវ៉ាលីដែរ តែអត់បានដាក់ទេព្រោះCharlene ប្រាប់ថាធ្លាប់បាត់វ៉ាលីកាបូប ខ្ញុំខ្លាចបាត់អត់លុយសង។ Precious បានសន្យាចំណាយថ្លៃធ្វើដំណើរថានឹងឲ្យខ្ញុំ$៥០០ដុល្លា និងឲ្យវត្ថុអនុស្សាវរីយ៍មួយចំនួន ទាក់ទងជាមិត្តភក្តិ។ កិច្ចសន្យាធ្វើពេលមកលើកទី២ គឺCharlene ជាអ្នកឲ្យចុះ ហើយនាងថានឹងយកឲ្យលោក ចាន់ ចុះហត្ថលេខាលើកទី២ ទើបចុះកិច្ចសន្យាជាមួយ Precious។ កាបូបដែលCharleneឲ្យគឺនៅ លើកទី៣ គឺជាក្រណាត់ចំលោក់ ជាលើកទី២ទេ។

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា: Precious ជាមិត្តប្រុសខ្ញុំស្គាល់គ្នា៥-៦ខែ។ កាបូបនេះ (សវនាការ) អត់ដឹងអ្នកណាជាម្ចាស់ប្រាកដទេ ខ្ញុំបានយកកាបូប១ទៅឲ្យTaylor ពុំដឹងមានគេដូររឺអត់ទេ ព្រោះនៅTaylor មួយល្ងាច។ កាបូបនេះមានគេយកមកផ្ទះ Precious ខ្ញុំយកទៅព្រោះ Precious សុំឲ្យខ្ញុំយកទៅឲ្យTaylor ខ្ញុំបានបើកមើលឃើញមានក្រណាត់អត់មានរូបចំលាក់នោះទេឲ្យថ្ងៃ១៨-០៩-២០១៣។ ពេលព្រឹកប្រហែលម៉ោង១១ខ្ញុំឲ្យ Taylor ប្រាប់ថាកាបូបមកពីក្រុមហ៊ុនKNN បានបើកមើលទាំងពីរនាក់ មានក្រណាត់ បានបើកចេញ បង្ហាញដែរ ខ្ញុំពុំបានប្រាប់ថាជារបស់មិត្តប្រុសទេ។ ម៉ោង១១យកទៅឲ្យ Taylor អ្នកកាន់ពេលដល់ព្រលាន ខ្ញុំបានប្រាប់ថាដាក់ជាប់ខ្លួនទៅមិនបាច់ដាក់លើយន្តហោះទេ។ Taylor ពុំបានបង្ហាញចង់យកឥវ៉ាន់ដាក់វ៉ាលីគាត់ទេ។ ខ្ញុំប្រាប់ឲ្យគាត់ស្គាល់ដោយ Precious ជាអ្នកឲ្យប្រាប់។ នៅ Airport ខ្ញុំចុះពីTaxi ជូនគាត់ត្រឹមច្រកចូល ខ្ញុំចាំខាងក្រៅព្រោះគាត់នឹងមកចេញលាខ្ញុំម្តងទៀតចាំប្រហែល១៥-២០នាទី អត់ឃើញខ្ញុំទៅសួរប៉ូលីស ប៉ូលីសប្រាប់ថាគាត់ប្រហែលជាចូលទៅបាត់ មានប៉ូលីសម្នាក់ទៀតមកនាំទៅជួប Taylor នៅចាំនាំទៅជាន់ទី១ឃើញ Taylor និងប៉ូលីស២-៣នាក់ ហើយបានឲ្យខ្ញុំអង្គុយដែរ បានសួរពី Precious ថានៅឯណា ប៉ូលីសប្រាប់ថាមានបញ្ហារឿងកាបូប ហើយប៉ូលីសកាត់កាបូបឃើញម្សៅជាគ្រឿងញៀន កាបូបនោះជាកាបូបនេះហើយ តែពុំច្បាស់ថាកាបូបនោះជាកាបូបខ្ញុំយកទៅរឺអត់ទេ។ NTO ខ្ញុំស្គាល់តែពុំជាមិត្តភក្តិទេ NTO ជាអ្នកយកកាបូបផ្ទាល់ខ្លួនមកផ្ទះPrecious ប្រហែលជាថ្ងៃទី១៦ ខែ០៩ ពេលហ្នឹងខ្ញុំនិងPreciousបើកឃើញក្រណាត់ពុំមែនជាកាបូបទទេនោះទេ ខ្ញុំអត់បានរៀបឥវ៉ាន់ដាក់ក្នុងកាបូបនោះទេ Precious ឲ្យយកកាបូបឲ្យ Taylor ថ្ងៃទី១៨ ពេលព្រឹកព្រោះគាត់ចេញទៅឲ្យគេក្រុងសក់។ បើកកាបូបពេលទទួល និងពេលឲ្យTaylor គឺឥវ៉ាន់ដូចគ្នា ខ្ញុំគ្មានអារម្មណ៍ថាធ្ងន់ទេ យកកាបូបចេញពេលថ្ងៃទី១៨ពេលព្រឹក។ រឿងថាPrecious ឲ្យយកកាបូបទៅឲ្យTaylor ថ្ងៃទី១៦ គឺគាត់គ្រាន់តែថាត្រូវយកឲ្យគេម្នាក់ត្រូវឡើងយន្តហោះ លុះថ្ងៃទី១៨ ទើបគាត់ថាយកឲ្យTaylor ផង។ ខ្ញុំអត់ទទួលប្រយោជន៍ពីគាត់ទេ មានតែរបស់ផ្ទាល់ខ្លួន ខ្ញុំអត់គិតថាPrecious ចំណាយលើTaylorទេ។ ខ្ញុំយកកាបូបឲ្យTaylor តាំងពីព្រឹកគឺខ្ញុំពុំ./.

មានតួនាទីជូនគាត់ទៅព្រលានទេ ម៉ោងប្រហែល៨និង៣០នាទីល្ងាច ទើប Precious ប្រាប់ខ្ញុំឲ្យជូន Taylor ទៅព្រលាន។ ថ្ងៃយកកាបូបទៅ Precious អត់ស្រវឹងទេ គាត់ស្រវឹងថ្ងៃ Taylor មកដល់គាត់មិនភ្ញាក់ ខ្ញុំទៅទទួល Taylor។ ខ្ញុំដឹងថាកាបូបមានតែក្រណាត់ ពុំជារបស់ខ្ញុំ ពុំមានប្រយោជន៍ខ្ញុំទេ តែPrecious ជាអ្នកប្រាប់ហើយវាមានតម្លៃនៅអូស្ត្រាលី ។ Mr Chan ធ្លាប់លឺ ឈ្មោះ អត់ស្គាល់ទេ ពេលទទួលTaylor គឺPrecious ឲ្យប្រាប់ថាខ្ញុំជាបុគ្គលិករបស់ Mr Chan ទើបស្គាល់នាងនៅពេលនោះហើយធ្លាប់ឃើញរូបថតលើទូរស័ព្ទ Precious ប្រហែល០២ថ្ងៃមុនទើបស្គាល់ [redacted] គាត់មកប្រមូលទំនិញទៅអូស្ត្រាលី។ ម៉ោង៣ភ្លឺ Precious មកផ្ទះវិញស្រវឹងបានផ្តាំឲ្យដាស់គាត់ម៉ោង៥ ព្រោះទៅរកTaylorម៉ោង៧ព្រឹក ខ្ញុំតេទៅNTOប្រាប់តែNTOឲ្យខ្ញុំទៅទទួលទៅវិញព្រោះថា Precious ស្រវឹងអត់ធ្វើការ, ខ្ញុំថាជាបុគ្គលិក Mr Chan ក្រុមហ៊ុនKNN ព្រោះ Precious ប្រាប់ចឹងពេលទៅទទួលនាង។ បន្ទាប់ពីជូនTaylor ទៅសណ្ឋាគារហើយ Precious ទៅជួប Taylor ពេលមកវិញ Precious ថាលែងចង់ជួប Taylor ពឹងខ្ញុំឲ្យជួបដោយថាជាបុគ្គលិកKNN ព្រោះគាត់អត់ត្រូវគ្នា។ Precious ឲ្យខ្ញុំជួយមើល Taylor នាំហូបបាយជាដើម។ ថ្ងៃ១៨ខ្ញុំយកកាបូប ចាំដល់១០នាទី Taylor ចុះមកខ្ញុំឲ្យកាបូបរួចលាគាត់។ ខ្ញុំប្រាប់គាត់កុំឲ្យដាក់កាបូបនៅយន្តហោះ គឺដោយ Precious ប្រាប់ខ្ញុំឲ្យប្រាប់គាត់តែអត់ប្រាប់ថាPreciousផ្តាំទេ រួចខ្ញុំចេញទៅភោជនីយដ្ឋានម្តាយខ្ញុំ ខ្ញុំជាអ្នកគ្រប់គ្រងជាមួយគាត់។ ជួបTaylorពេលល្ងាចនៅសណ្ឋាគារខារ៉ា ពុំបានជួយយួរកាបូបទេ ពេលទៅដល់ព្រលានខ្ញុំចាំគាត់ដោយគាត់មកលាគ្នា។ ពេលស្គាល់Preciousដំបូងខ្ញុំ ដឹងថាគាត់ជាអ្នករកស៊ីនាំចេញនាំចូលមានគ្រឿងអេឡិចត្រូនិច កំរាលពូក។ Preciousជាអ្នកហៅ Taylorមកកម្ពុជា ដើម្បីយកគំរូក្រណាត់ទៅលក់នៅអូស្ត្រាលី អត់ដឹងថាមានបារាំងឬអត់ទេ បើថានឹងបើក។ កិច្ចសន្យាលើកទី១ ខ្ញុំអត់ដឹងទេ,លើកទី២ Precious ឲ្យខ្ញុំយកទៅឲ្យTaylorចុះហត្ថលេខារួចម្នាងទៀតមានហត្ថលេខារួច អត់ដឹងថាជារបស់នរណាទេ អត់មានលុយទេបង្កាន់ដៃប្រាក់នោះខ្ញុំអត់ដឹងទេ។ ពេលយកកាបូបពីផ្ទះPrecious ខ្ញុំបានជិះកង់ទៅឆ្លៀតចូលភោជនីយដ្ឋាន យកកុំព្យូទ័រខ្ញុំទើបចេញទៅសណ្ឋាគារ។ ខ្ញុំអត់ដឹងថាកាបូបដដែលដែលខ្ញុំយកឲ្យTaylor រឺអត់ទេពេលTaylorទៅព្រលានអត់ដឹងថាមានកាបូបប៉ុន្មានទេ។

-សមត្ថកិច្ច លោកគង់ណារិទ្ធ បានឆ្លើយថា: ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៣ការិយាល័យទទួលព័ត៌មានទៅអូស្ត្រាលីបានឃាត់ខ្លួន Cathryn និង David ចាប់គ្រឿងញៀនក្នុងកុំព្យូទ័រ យួរដៃទទួលពី [redacted] ក្រោយមកសង្ស័យបានចុះនៅប្រៃសណីយ៍វត្តភ្នំបានលេខទូរស័ព្ទ ០៩៧ ៩៥៩៩២៣៦ ជាលេខជនជាតិស្បែកខ្មៅ និងលិខិតឆ្លងដែន Precious Mart តែឆែកឆេរអត់ឃើញ តែផ្ទៀងរូបថតឃើញលិខិតឆ្លងដែនដែលមានពត៌មានឈ្មោះ [redacted] CHINEME និងស៊ើបដឹងពីCharlene នៅក្នុងភោជនីយដ្ឋាន ហើយបានដាក់កំលាំងតាមដានរហូតដល់ផ្ទះPrecious ជិះរថយន្តសេលេកា, Charlene ជិះកង់បី។ លេខ០៩៧ខាងលើជារបស់ជនជាតិប៊ែលហ្សិក សង្សារដំបូងរបស់ Precious។ ម៉ោង១១និង៥៥នាទីថ្ងៃ១៨-០៩-២០១៣ Charlene យួរកាបូប១នេះជិះកង់បីទៅសណ្ឋាគារខារ៉ា ប្រហែល២០នាទីបានចេញមកវិញអត់យកកាបូបចេញមកទេ ម៉ោង៦និង១៥នាទីបានដាក់កំលាំងនៅសណ្ឋាគារបានឆែកដឹងថា Taylor ត្រូវចេញមានសំបុត្រយន្តហោះក៏តាមដល់ព្រលានយន្តហោះ Taylorស្ពាយកាបូប និងមានវ៉ាលីពណ៌ផ្កាឈូកដាក់ត្រួតពិនិត្យ ឯCharleneនៅចាំមើលTaylorនៅព្រលាន ឯឈ្មោះPreciousចេញផុតហើយគាត់បានដឹកជនជាតិកាណាដាម្នាក់ចេញបាត់។ កំលាំងនៅផ្ទះPreciousឃើញគាត់ចូលផ្ទះបានព័ទ្ធចាប់។ ពេលវះកាបូប Charlene អត់បាននៅទេ ក្រោយមកទើបគាត់ឃើញវត្ថុតាងកាបូបវះ។ ឃាត់បានស្ត្រីជនជាតិកាណាដាម្នាក់ដែលទើបមកដល់ប្រទេសកម្ពុជា តែគាត់អត់ដឹងរឿងទេ ឈ្មោះ [redacted] ពេលScanកាបូបអាចដឹង តែបើដាក់វត្ថុរឹងម៉ាស៊ីនScanតែវត្ថុអត់Scanកាបូបទេ។

ក្នុងកាបូបដាក់ក្រណាត់ គ្រឿងញៀនដាក់ក្នុងជញ្ជាំងកាបូប មើលនឹងភ្នែកពុំអាចដឹងទេ តែកាបូបធ្ងន់ប្លែកពីធម្មតា។ NTO ត្រូវបានកំណត់អត្តសញ្ញាណ តែដោយកំលាំងតិច កន្លែងបង្ក្រាបច្រើន ធ្វើការពេលយប់ជ្រៅផង លុះស្នើកNTOបានគេចខ្លួនបាត់ NTOជាកូនចៅរបស់Precious គឺគាត់ជិះម៉ូតូតាមឡានPrecious ដូចអង្គរក្ស។ [redacted] ធ្លាប់មកខ្មែរដែរ។ បន្ទាប់ពី Charlene ចេញពីសណ្ឋាគារខារ៉ា ពុំដឹងអ្នកណាទៅជួប Taylor ខ្លះទេ ព្រោះកំលាំងឃ្លាំតែ Charlene និងPrecious។ កាបូបវះនៅមុខTaylor គឺដកក្រណាត់ចេញ ថ្លឹងកាបូបទើបវះកាបូបការដាក់នោះគឺប្រើម៉ាស៊ីនដេរជំនាញទើបអាចធ្វើការបាន។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងតាមការសួរដេញដោល ការស្តាប់លទ្ធផលកោសល្យវិច័យ ឃើញថាជនជាប់ចោទទាំងបីពិតជាបានប្រព្រឹត្តអំពើដឹកជញ្ជូនពេលសមត្ថកិច្ចចុះបង្ក្រាប ហេតុនេះឃើញថាជនជាប់ចោទទាំងប្រាំនាក់ មានពិរុទ្ធភាពពីបទដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន (ឆ្លងដែន) ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦-១៨ ខែកញ្ញា ឆ្នាំ២០១៣ ហេតុនេះតំណាងអយ្យការនៅតែតម្កល់តាមដីកាសន្និដ្ឋានស្ថាពរ លេខ ២០៤ អ.យ.ង ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២១០៤ ទុកជាបានការដដែល។

-មេធាវីការពារសិទ្ធិជនជាប់ចោទលោក [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា: តាមចម្លើយជនទាំងបីឃើញថាកាបូប គឺNTO ជាអ្នកទិញ Sarvarino ជាអ្នកដឹងលឺនៅពេលទទួលគាត់ផែកផ្ទៀងផ្ទាត់ពុំមានអ្វីទេ កាបូបចេញពីផ្ទះPrecious ពេលព្រឹកទើបល្ងាចទៅព្រលាន ពុំដឹងគេដូរវ៉ាលីរឺអត់ទេ ហើយ Charlene ក៏ពុំដឹងច្បាស់កាបូបនេះរឺអត់ទេ ពេលផែកឆេរចាប់ខ្លួនពុំមានគ្រឿងញៀនទេលើកូនក្តី ក៏ពុំមានគេចវេសដូចNTOទេ ហើយPrecious ពុំបានទៅឃ្លាំមើលTaylor និង Charlene ដែរ គឺទៅទទួលគេ Precious អត់បានតាមដានកាបូបយកទៅនោះទេ ការចាប់រឿងគ្រឿងញៀនទាល់តែមានគ្រឿងញៀនប៉ុន្តែអត់មានភស្តុតាងនៅជាមួយកូនក្តី សុំតុលាការឲ្យកូនក្តីរួចផុតពីបទចោទ។

-មេធាវីការពារសិទ្ធជនជាប់ចោទ [redacted] [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីស្តាប់ការសួរដេញដោល ឃើញថាកូនក្តី Taylor ជាជនរងគ្រោះម្នាក់ គាត់ដំបូងបែកបាក់គ្រួសារ ជួប Precious តាមInternet សន្យាបើកបាងឲ្យប្រាក់ខែ ដែលមានកិច្ចសន្យាចុះថ្ងៃទី ១៦-០៩-២០១៣ កិច្ចសន្យាការងារលក់វត្ថុអនុស្សាវរីយនៅអូស្ត្រាលីដើម្បីចំណេញ។ កាបូបកូនក្តីពុំមានអ្វីទេ ព្រោះឃើញតែក្រណាត់ កូនក្តីត្រូវ Precious និងNTO ប្រាប់ ពេលឃាត់ខ្លួនគាត់បានសហការណ៍បានប្រគល់កាបូបឱ្យសមត្ថកិច្ចឆែកឆេរ គឺគាត់ស្មោះត្រង់ពុំបានធ្វើ។ តាមលិខិតទទួលប្រាក់ខែកូនក្តីលិខិតស្នើសុំទៅក្រុនហ៊ុនKNN ប្រាក់បើកបាង លិខិតជូលទីតាំងជាប្លង់កន្លែងត្រូវបើក រហូតដល់កំណត់តំលៃ០៥ម៉ឺនដុល្លាអាមេរិក រយៈពេល០៦ខែជាសន្យាខ្យល់ ពុំទាន់មានផលប្រយោជន៍ដល់កូនក្តីទេ។ កូនក្តីគ្រាន់តែជាជនរងគ្រោះ ត្រូវគេអូសទាញ ពុំមានពាក់ព័ន្ធរឿងគ្រឿងញៀនទេ សុំឲ្យកូនក្តីរួចខ្លួនពីបទចោទ

-លោកស្រីមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីអត់បានប្រព្រឹត្តទេ កូនក្តីធ្វើការនៅ Le Do Resterant [redacted] នជំងឺបាក់ឆ្អឹង បាក់ទឹកចិត្ត កូនក្តីរាប់អាន Precious ដោយជឿទុកចិត្តនិងដឹងថា Precious រកស៊ីនាំចេញនាំចូលតាមប្រៃសនីយ៍ត្រឹមត្រូវ កូនក្តីពុំពាក់ព័ន្ធជំនួញពុំបានប្រយោជន៍ទេ គឺ Precious ពឹងឲ្យជួយគាត់ គាត់ក៏ជួយអត់ដឹងថាជារបស់អ្វីដែរគ្រាន់តែជួយ Precious ហើយ Precious បានឆ្លើយថា ខ្លួនជាអ្នកត្រូវយកទៅ។ កូនក្តីឆែកមើលឃើញតែក្រណាត់ ហើយចេញវិញ កាបូបនៅ Taylor លុះល្ងាចទើបកូនក្តីទៅជូនTaylor ពេលនៅព្រលានកូនក្តីបាននៅទីនោះរងចាំ Taylor លាគ្នា កូនក្តីពុំអះអាងថាកាបូបនេះរឺអត់ទេដែលខ្លួនយកទៅជំនួស Precious កូនក្តីពុំបានដឹងទេ។ តាមមាត្រា៨នៃក្រមព្រហ្មទណ្ឌ, មាត្រា៣៨នៃរដ្ឋធម្មនុញ្ញ និងមាត្រា

២៤ នៃក្រមព្រហ្មទណ្ឌ សុំលើកលែងចោទប្រកាន់។

-លោកមេធាវី [redacted] បានធ្វើសេចក្តីថ្លែងការណ៍ថា: កូនក្តីឈ្មោះ NTO គ្រាន់តែជាអ្នកទិញកាបូបឲ្យមិត្តភក្តិ និងយកទៅឲ្យឈ្មោះ Precious ពុំមានពាក់ពន្ធនិងរឿងក្តីនេះទេ ហើយក៏ពុំមានភស្តុតាងណាបញ្ជាក់ថា កូនក្តីបានប្រព្រឹត្តដូចការចោទប្រកាន់ តាមមាត្រា៣៨-៦នៃរដ្ឋធម្មនុញ្ញ, មាត្រា៣៥១ នៃក្រមព្រហ្មទណ្ឌ សុំតុលាការឲ្យកូនក្តីរួចផុតពីបទចោទ។ កូនក្តីឈ្មោះ ASEMOTA ពុំមានលីឈ្មោះនាពេលសួរដេញដោលក្នុងសវនាការ ហេតុនេះពុំមានពាក់ព័ន្ធនឹងសំណុំរឿងនេះទេ ហេតុនេះសុំឲ្យតុលាការសំរេចឲ្យរួចផុតពីបទចោទ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] [redacted]: សុំរកយុត្តិធម៌ និងដោះលែងឲ្យមានសេរីភាពឡើងវិញ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] [redacted]: សុំដោះលែងឲ្យមានសេរីភាពឡើងវិញ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted]: សុំដោះលែងឲ្យមានសេរីភាពវិញ។

## **<u>សំអាងហេតុ:</u>**

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយសាក្សីបំភ្លឺជាសមត្ថកិច្ចចុះបង្ក្រាប

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារភស្តុតាង

-ក្រោយពីបានពិនិត្យពិចារណាសំណុំរឿងសព្វគ្រប់ ឃើញថា:

-កាលពីថ្ងៃទី១៦ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ នៅចំណុច រាជធានីភ្នំពេញ មានករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន (ឆ្លងដែន) មួយបានកើតឡើង។

-ជនជាប់ចោទឈ្មោះ: [redacted] [redacted] ភេទប្រុស អាយុ២៣ឆ្នាំ ជាតិនីហ្សេរីយ៉ា, ឈ្មោះ: [redacted] ភេទស្រី អាយុ១៩ឆ្នាំ ជាតិបារាំង, ឈ្មោះ: [redacted] ភេទស្រី អាយុ៥១ឆ្នាំ ជាតិអូស្ត្រាលី, ឈ្មោះ: [redacted] MATINS ហៅ NTO ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិនីហ្សេរីយ៉ា និងឈ្មោះ: [redacted] OSAHENI ភេទប្រុស កើតថ្ងៃទី១២-០៧-១៩៨៥ (តាមលិខិតPerson Report "ឯកសារលេខ៤៩/៩") ជាតិនីហ្សេរីយ៉ា ជានីតិជន និងជាជនមានសមត្ថភាពអាចទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌបាន។

-ជនជាប់ចោទឈ្មោះ: [redacted] បានឆ្លើយថា: កាបូបគឺ NTO ជាអ្នកទិញមកឱ្យខ្លួននៅថ្ងៃទី១៦ សំរាប់ដាក់វត្ថុសិល្បៈទុកផ្ញើរទៅអូស្ត្រាលី ពេលយកមកកាបូបអត់មានអ្វីទេ បន្ទាប់មកខ្លួនជូនNTOទៅផ្សារដើរទិញឥវ៉ាន់ដាក់ចូលសម្រាប់អតិថិជនគាត់គឺទិញសំលៀកបំពាក់ប្រពៃណី ក្រណាត់ រួចយកទៅទុកនៅផ្ទះវិញ។ នៅថ្ងៃទី១៨ ខ្លួនបានឱ្យ Savarino យកកាបូបនេះទៅប្រគល់ឱ្យTaylor ហើយខ្លួនមិនដែលឱ្យលុយទៅSavarino ទេ។ ក្នុងការផ្ញើគឺខ្លួនត្រូវបានចំនួន៣០០០$ប៉ុន្តែខ្លួនមិនទាន់ទទួលបានទេ។

-ជនជាប់ចោទឈ្មោះ: [redacted], ឈ្មោះ: [redacted] និងឈ្មោះ: [redacted] [redacted] បានឆ្លើយប្រហាក់ប្រហែលគ្នាថា: កាបូបខ្មៅជាកាបូបដាក់វត្ថុសិល្បៈពីដើម្បីយកទៅប្រទេសអូស្ត្រាលី ដែលកាបូបនេះ Precious ត្រូវយកទៅឱ

ប្រគល់ឱ្យ Taylor ដែលជាអ្នកនាំយកទៅប្រទេសអូស្ត្រាលី ប៉ុន្តែ Precious ដោយជាប់រវល់ បានឱ្យមិត្តស្រីខ្លួនឈ្មោះ Savarino យកទៅប្រគល់ឱ្យ Taylor នៅសណ្ឋាគារខារ៉ា ដែលទង្វើនេះជាការសហការគ្នាក្នុងការបញ្ជូនដែលធ្វើឱ្យមានការផ្លាស់ទី នៃកាបូបខ្មៅដែលជាវត្ថុតាងក្នុងសំណុំរឿង។ វត្ថុតាងកាបូបខ្មៅដែលសមត្ថកិច្ចឃាត់បាននៅលើខ្លួនឈ្មោះ Tayor មានបង្កប់នូវគ្រឿងញៀនប្រភេទហេរ៉ូអ៊ីនទម្ងន់២០០២,៤០ក្រាម។ ម្យ៉ាង Taylor បានឆ្លើយថាខ្លួនធ្លាប់ទទួលបានប្រាក់ក្នុងការផ្ញើវត្ថុសិល្បៈកាលខ្លួនមកកម្ពុជាលើកទី២ ចំនួន ១០០០$ (មួយពាន់ដុល្លាអាមេរិក) ចំណែកឯ Precious ក៏បានឆ្លើយដែរថាខ្លួនត្រូវបានប្រាក់ចំនួន ៣០០០$ (បីពាន់ដុល្លាអាមេរិក) ក្នុងការបញ្ជូននេះ មួយវិញទៀតជនជាប់ចោទទាំងបីបានឆ្លើយដូចៗគ្នាថាឱ្យ Taylor ទុកកាបូប ជាប់នឹងខ្លួនព្រោះខ្លាចបាត់ បើទោះបីជា Taylor ឆ្លើយថាខ្លួនខ្លាចបាត់ព្រោះអត់លុយសង វាគ្រាន់តែជាចម្លើយឆ្លើយដោះសារតែប៉ុណ្ណោះ។ ហេតុនេះការឆ្លើយដោះសាររបស់ជនជាប់ចោទទាំងបីនាក់ ដែលថាគ្រាន់តែបញ្ជូនកាបូបដាក់វត្ថុសិល្បៈទៅប្រទេសអូស្ត្រាលីមិនអាចឱ្យតុលាការជឿបានឡើយ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted] បានឆ្លើយដូចៗគ្នាថាកាបូបគឺឈ្មោះ NTO ជាអ្នកយកមកប្រគល់ ឱ្យ Precious នៅផ្ទះ ហើយបើតាមចម្លើយរបស់ Precious បានឆ្លើយថា NTO បានយកមកឱ្យខ្លួនបានចំនួនបីដង ហើយ NTO ជាអ្នកប្រាប់ខ្លួនឱ្យប្រាប់ទៅ Taylor ឱ្យទុកកាបូបជាប់ខ្លួនកុំឱ្យបាត់ ម្យ៉ាងតាមចម្លើយរបស់សមត្ថកិច្ច គង់ ណារិទ្ធ បានឆ្លើយដែរថាឈ្មោះ NTO ត្រូវបានកំណត់អត្តសញ្ញាណបាន តែដោយកំលាំងតិចកន្លែងបង្ក្រាបច្រើននិងធ្វើការពេលយប់ផងទើបឈ្មោះនេះមានឱកាសរត់គេចខ្លួន ហើយ NTO ជាកូនចៅរបស់ Precious ដែលតែងជិះម៉ូតូតាមឡានPrecious ដូចអង្គរក្ស។

-តាមចម្លើយរបស់ [redacted] នៅដំណាក់កាលចៅក្រមស៊ើបសួរកាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ បានឆ្លើយថា: ខ្ញុំត្រូវទិញរបចំលាក់ពីស្រុកខែរទៅឱ្យ Taylor លក់នៅប្រទេសអូស្ត្រាលីដោយឱ្យឈ្មោះ [redacted] ជាអ្នកលក់។ [redacted] EDO មានឈ្មោះពេញថា [redacted] តាមចម្លើយរបស់ Precious មានន័យថាឈ្មោះ [redacted] ជាអ្នកចាំទទួលទំនិញពី Taylor ពីស្រុកខ្មែរ។ ហើយតាមរបាយការណ៍វាស់ឃោតលេខ ១៣១ សសណ/១៣ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៣ របស់ការិយាល័យឧក្រិដ្ឋកម្មឆ្លងដែនបានបញ្ជាក់ឱ្យថា Precious បានធ្វើការផ្ញើកាបូបដៃ និងកាបូបស្ពាយចំនួន០៦លើក ដែលលើកទី១,ទី២,ទី៤ គឺប្រគល់ឱ្យទៅឈ្មោះ [redacted]

-ជនជាប់ចោទបានឆ្លើយបដិសេធថាខ្លួនមិនបានដឹងថាកាបូបមានគ្រឿងញៀន ដោយថាជាកាបូបសំរាប់ដាក់គ្រឿងចំលាក់ក៏ដោយ ប៉ុន្តែតាមចម្លើយរបស់សាក្សីជាសមត្ថកិច្ច, តាមរបាយការណ៍ និងភស្តុតាងនានាក្នុងសំណុំរឿងបញ្ជាក់ឱ្យឃើញថាជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើ ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន (ឆ្លងដែន) ប្រាកដមែន។

-មេធាវីការពារសិទ្ធិជនជាប់ចោទលោក ផេង ឈាង បានធ្វើសេចក្តីសន្និដ្ឋានថា: កាបូបគឺNTO ជាអ្នកទិញ Sarvarino ជាអ្នកដឹងលឺនៅពេលទទួល គាត់ឆែកផ្ទៀងផ្ទាត់ពុំមានអ្វីទេ កាបូបចេញពីផ្ទះPrecious ពេលព្រឹកទើបល្ងាចទៅព្រលាន ពុំដឹងគេដូរវ៉ាលីអត់ទេ ហើយ Charlene ក៏ពុំដឹងច្បាស់កាបូបនេះរឺអត់ទេ ពេលឆែកឆេរចាប់ខ្លួនពុំមានគ្រឿងញៀនទេលើកូនក្តី ក៏ពុំមានគេចវេសដូចNTOទេ ហើយPrecious ពុំបានទៅឃ្លាំមើលTaylor និង Charlene ដែរ គឺទៅទទួលគេ Precious អត់បានតាមដានកាបូបយកទៅនោះទេ ការចាប់រឿងគ្រឿងញៀនទាល់តែមានគ្រឿងញៀនប៉ុន្តែអត់មានភស្តុតាងនៅជាមួយកូនក្តី សុំតុលាការឲ្យកូនក្តីរួចផុតពីបទចោទ គប្បីតុលាការមិនពិចារណា។

-មេធាវីការពារសិ[redacted]ជនជាប់ចោទ [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តី Taylor ជាជនរងគ្រោះម្នាក់ គាត់ដំបូងបែកបាក់គ្រួសារ ជួប Precious តាមInternet សន្យាបើកបាងឲ្យប្រាក់ខែ ដែលមានកិច្ចសន្យាចុះថ្ងៃទី១៦-០៩-២០១៣ កិច្ចសន្យាការងារលក់វត្ថុអនុស្សាវរីយ នៅអូស្ត្រាលីដើម្បីចំណេញ។ កាបូបកូនក្តីពុំមានអ្វីទេ ព្រោះឃើញតែក្រណាត់។ តាមបេឋិខិតទទួលប្រាក់ខែកូនក្តី លិខិតស្នើសុំទៅក្រុនហ៊ុនKNN ប្រាក់បើកបាង លិខិតជួលទីតាំងជាប្លង់កន្លែងត្រូវបើក រហូតដល់កំណត់តំលៃ០៥ម៉ឺនដុល្លាអាមេរិក រយៈពេល០៦ខែជាសន្យាខ្យល់ ពុំទាន់មានផលប្រយោជន៍ដល់កូនក្តីទេ។ កូនក្តីគ្រាន់តែជាជនរងគ្រោះត្រូវគេអូសទាញ ពុំមានពាក់ព័ន្ធរឿងគ្រឿងញៀនទេ សុំឲ្យកូនក្តីរួចខ្លួនពីបទចោទ តប្បីតុលាការមិនពិចារណា។ នៅពេលឃាត់ខ្លួនកូនក្តីបានសហការណ៍បានប្រគល់កាបូបឱ្យសមត្ថកិច្ចដែរនេរ គឺគាត់ស្មោះត្រង់ពុំបានធ្វើ តប្បីតុលាការពិចារណា។

-លោកស្រីមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីអត់បានប្រព្រឹត្តទេ កូនក្តីធ្វើការនៅ Le Do Resterant កូនក្តីពុំពាក់ព័ន្ធជំនួញ ពុំបានប្រយោជន៍ទេ គឺ Precious ពឹងឲ្យជួយគាត់ គាត់ក៏ជួយអត់ដឹងថាជារបស់អ្វីដែរគ្រាន់តែជួយPrecious ហើយ Precious បានឆ្លើយថា ខ្លួនជាអ្នកត្រូវយកទៅ។ កូនក្តីឆែកមើលឃើញតែក្រណាត់ហើយចេញវិញ កាបូបនៅ Taylor លុះល្ងាចទើបកូនក្តីទៅជូនTaylor ពេលនៅព្រលានកូនក្តីបាន នៅទីនោះរងចាំ Taylor លាគ្នាកូនក្តីពុំអះអាងថាកាបូបនេះវីអត់ទេដែលខ្លួនយកទៅជំនួស Precious កូនក្តីពុំបានដឹងទេ។ តាមមាត្រា៨ នៃក្រមព្រហ្មទណ្ឌ, មាត្រា៣៨នៃរដ្ឋធម្មនុញ្ញ និងមាត្រា២៨ នៃក្រមព្រហ្មទណ្ឌ សុំលើកលែងចោទប្រកាន់ តប្បីតុលាការមិនពិចារណា។

-លោកមេធាវី [redacted] [redacted] បានធ្វើសេចក្តីថ្លែងការណ៍ថា: កូនក្តីឈ្មោះ NTO គ្រាន់តែជាអ្នកទិញកាបូបឲ្យមិត្តភក្តិ និងយកទៅឲ្យឈ្មោះ Precious ពុំមានពាក់ពន្ធនិងរឿងក្តីនេះទេ ហើយក៏ពុំមានភស្តុតាងណាបញ្ជាក់ថា កូនក្តីបានប្រព្រឹត្តដូចកាចោទប្រកាន់ តាមមាត្រា៣៨-៦នៃរដ្ឋធម្មនុញ្ញ, មាត្រា៣៥១ នៃក្រមព្រហ្មទណ្ឌ សុំតុលាការឲ្យកូនក្តីរួចផុតពីបទចោទ។ កូនក្តីឈ្មោះ ASEMOTA ពុំមានលឺឈ្មោះនាពេលសួរដេញដោលក្នុងសវនាការ ហេតុនេះពុំមានពាក់ព័ន្ធនឹងសំណុំរឿងទេ ហេតុនេះសុំឲ្យតុលាការសំរេចឲ្យរួចផុតពីបទចោទ តប្បីតុលាការមិនពិចារណា។

-តាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ៣០៨៩ម.ព.អ.ជ.ប.គ.ញ ចុះ ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤ បញ្ជាក់ថា៖ វិជ្ជមាន, វត្ថុមានសារធាតុញៀនឈ្មោះ ហេរ៉ូអ៊ីន (Heroine) គិតជាភាគរយនៃទម្ងន់គឺ ៦៣,៨២% (ហុកសិបបី ក្បៀសប៉ែតសិបពីរភាគរយ) ដែលមានបរិមាណសារធាតុសុទ្ធសរុប ២០០២,៨០g x ៦៣,៨២% = ១២៧៧,៩៣g (មួយពាន់ពីររយចិតសិបប្រាំពីរ ក្បៀសកៅសិបបីក្រាម)។

-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted] CHARLENE, ឈ្មោះ [redacted], ឈ្មោះ [redacted] ហៅ NTO និងឈ្មោះ [redacted] គឺជាការបញ្ជូនដែលនាំឱ្យមានការផ្លាស់ទី ពីទីកន្លែងមួយទៅទីកន្លែងមួយទៀតពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ឬពីប្រទេសមួយទៅប្រទេសមួយទៀតដោយខុសច្បាប់នូវសារធាតុញៀន ជាអាទិ៍ តាមរយៈការធ្វើចរាចរ ការនាំចេញ គឺជាអំពើ ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា: [redacted] ភេទប្រុស អាយុ២៣ឆ្នាំ ជាតិនីហ្សេរីយ៉ា, ឈ្មោះ [redacted] ភេទស្រី អាយុ១៩ឆ្នាំ ជាតិបារាំង, ឈ្មោះ [redacted] ភេទស្រី អាយុ៤១ឆ្នាំ ជាតិអូស្ត្រាលី,

ឈ្មោះ [redacted] ហៅ NTO ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិនីហ្សេរីយ៉ា និងឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី១២-៧-១៩៨៥ (តាមលិខិត Person Report ឯកសារលេខ៤៩/៩) ជាតិនីហ្សេរីយ៉ា ពិតជាបានប្រព្រឹត្តអំពើ ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន (ឆ្លងដែន) ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៦ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសារភាពថាខ្លួនជាអ្នកទទួលកាបូបពីឈ្មោះ [redacted] និងជាអ្នកកាន់កាបូបទៅព្រលានយន្តហោះ ដើម្បីបញ្ជូនកាបូបទៅប្រទេស អូស្ត្រាលី និង នសហការជាមួយសមត្ថកិច្ចរហូតឈានដល់ការឃាត់ខ្លួនឈ្មោះ [redacted] និងឈ្មោះ [redacted] គប្បីតុលាការពិចារណាពីស្ថានសម្រាលទោសដល់ជនជាប់ចោទ។

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសារភាពថាខ្លួនជាអ្នកយកកាបូបបេគល់ឱ្យទៅឈ្មោះ [redacted] ហើយដោយសារឈ្មោះ NWOKO [redacted] ត្រូវជាមិត្តប្រុសបានពឹងឱ្យយកទៅឱ្យជំនួស គប្បីតុលាការពិចារណាពីស្ថានសម្រាលទោសដល់ជនជាប់ចោទ។

-វត្ថុតាងដូចមាននៅក្នុង កំណត់ហេតុទទួលវត្ថុតាងលេខ ៥៩២វ.ត ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៣ របស់ឃ្លាំងតម្កល់វត្ថុតាងរបស់សាលាដំបូងរាជធានីភ្នំពេញរួមមាន:

ក.ហឹបដែកពណ៌សបិទជិតមានហត្ថលេខាគណៈកម្មការចូលរួមធ្វើការវេចខ្ចប់វត្ថុតាង និងស្នាមមេដៃជនសង្ស័យ។ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លេខ ១៧៦៩ អ.យ.ង ចុះថ្ងៃទី២៣-៩-២០១៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បញ្ជាក់ថា៖ ម្សៅហេរ៉ូអ៊ីន ទម្ងន់ ២០០២,៤០(ពីរពាន់ពីរក្រៀសសែសិប)ក្រាម។

ខ.ក្រដាសពណ៌ក្រហមវេចខ្ចប់គ្រឿងញៀន និងកាបូបស្ពាយពណ៌ខ្មៅមួយ។

ជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេចរឹបអូស។

គ.ទូរស័ព្ទដៃម៉ាក HTC ពណ៌ខ្មៅមួយគ្រឿង, ទូរស័ព្ទដៃម៉ាក HUAWEI ពណ៌សមួយគ្រឿង, ទូរស័ព្ទដៃម៉ាកសាំសុង GALAXY ពណ៌សមួយគ្រឿង និងទូរស័ព្ទដៃម៉ាកសាំសុងសេរីចាស់ គ្មានថ្មចំនួន មួយគ្រឿង។

ឃ.លិខិតឆ្លងដែនរបស់ឈ្មោះ [redacted] លេខ A01722130។

ង.លិខិតឆ្លងដែនរបស់ឈ្មោះ [redacted] លេខ A01047063។

ច.លិខិតឆ្លងដែនរបស់ឈ្មោះ [redacted] លេខ N42772461។

ឆ.ម៉ូតូម៉ាក AIR BLADE ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1AB 5138 មួយគ្រឿង។

ជ.រថយន្តម៉ាក CILECA ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 2C 3335 ចំនួនមួយគ្រឿង។

ឈ.កុំព្យូទ័រយួរដៃម៉ាក ASUS ពណ៌ខ្មៅ មួយគ្រឿង។

ញ. កាបូបដៃចាស់ ១ ០២។

ដ.លោហធាតុពណ៌សមួយចំនួន (ខ្សែក ក្រវិល....)។

ឋ.ឯកសារមួយចំនួន។

ឌ.ឧបករណ៍អេឡិចត្រូនិចពណ៌ខ្មៅ ចំនួន ០២គ្រឿង។

ឍ.កុំព្យូទ័រយួរដៃម៉ាក La Vie ពណ៌ស មួយគ្រឿង។

ណ.ឧបករណ៍សម្រាប់សាកថ្មមួយចំនួន។

ត.ឧបករណ៍ម៉ាក hard drive by HITACHI ចំនួន ០១គ្រឿង។

ថ.នាឡិកាដៃចំនួន ០៦គ្រឿង។

ទ.ប្រាក់ដុល្លាអាមេរិកចំនួន ៨៦១$(ប្រាំបីរយហុកសិបមួយដុល្លាអាមេរិក)។

ធ.កាបូបស្ពាយសម្រាប់ដាក់កុំព្យូទ័រយួរដៃ ០១។

ន.វ៉ាលីដាក់ខោអាវ ០២។

ពុំមែនជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោស៖

ក.ឈ្មោះ [redacted] ភេទប្រុស អាយុ២៣ឆ្នាំ ជាតិនីហ្សេរីយ៉ា (NIGERIAN) ដាក់ពន្ធនាគារកំណត់ចំនួន ២៧(ម្ភៃប្រាំពីរ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨០.០០០.០០០(ប៉ែតសិបលាន)រៀល។

ខ.ឈ្មោះ [redacted] ភេទស្រី អាយុ១៩ឆ្នាំ ជាតិបារាំង ដាក់ពន្ធនាគារកំណត់ចំនួន ២៥(ម្ភៃប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០.០០០.០០០(ហាសិបលាន)រៀល។

គ.ឈ្មោះ [redacted] ភេទស្រី អាយុ៥១ឆ្នាំ ជាតិអូស្ត្រាលី ដាក់ពន្ធនាគារកំណត់ចំនួន ២៣(ម្ភៃបី)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០.០០០.០០០(ហាសិបលាន)រៀល។

ឃ.ឈ្មោះ [redacted] ហៅ NTO ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិនីហ្សេរីយ៉ា ដាក់ពន្ធនាគារកំណត់ចំនួន ២៧(ម្ភៃប្រាំពីរ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨០.០០០.០០០(ប៉ែតសិបលាន)រៀល។

ង.ឈ្មោះ [redacted] ភេទប្រុស ជាតិនីហ្សេរីយ៉ា ដាក់ពន្ធនាគារកំណត់ចំនួន ២៧(ម្ភៃប្រាំពីរ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨០.០០០.០០០ (ប៉ែតសិបលាន) រៀល។

ពីបទ ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន (ឆ្លងដែន) ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted]S ហៅ NTO និងឈ្មោះ [redacted]NI យកមកទទួលទោសតាមអំណាចសាលក្រមនេះ តាមបញ្ញត្តិមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣-វត្ថុតាងដូចមាននៅក្នុង កំណត់ហេតុទទួលវត្ថុតាងលេខ ៥៩២វ.ត ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៣ របស់ឃ្លាំងតម្កល់វត្ថុតាងរបស់សាលាដំបូងរាជធានីភ្នំពេញរួមមាន:

ក.ហិបដែកពណ៌សបិទជិត មានហត្ថលេខាគណៈកម្មការចូលរួមធ្វើការវេចខ្ចប់វត្ថុតាង និងស្នាមមេដៃជនសង្ស័យ។ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លេខ ១៧៦៩ អ.យ.ង ចុះថ្ងៃទី២៣-៩-២០១៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បញ្ជាក់ថា៖ មេថ្យាំហ្វេតាមីន ទម្ងន់ ២០០២,៥០(ពីរពាន់ពីរក្បៀសហាសិប)ក្រាម។

ខ.ក្រដាសពណ៌ក្របាមវេចខ្ចប់គ្រឿងញៀន និងកាបូបស្ពាយពណ៌ខ្មៅមួយ។

ត្រូវរិបអូស។

គ.ទូរស័ព្ទដៃម៉ាក HTC ពណ៌ខ្មៅមួយគ្រឿង, ទូរស័ព្ទដៃម៉ាក HUAWEI ពណ៌សមួយគ្រឿង, ទូរស័ព្ទដៃម៉ាកសាំសុង GALAXY ពណ៌សមួយគ្រឿង និងទូរស័ព្ទដៃម៉ាកសាំសុងសេរីចាស់ គ្មានថ្មចំនួនមួយគ្រឿង។

ឃ.លិខិតឆ្លងដែនរបស់ឈ្មោះ [redacted] លេខ A01722130។

ង.លិខិតឆ្លងដែនរបស់ឈ្មោះ [redacted]S លេខ A010470063។
ច.លិខិតឆ្លងដែនរបស់ឈ្មោះ [redacted] ANN លេខ N42772461។
ឆ.ម៉ូតូម៉ាក AIR BLADE ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1AB 5138 មួយគ្រឿង។
ជ.រថយន្តម៉ាក CILECA ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 2C 3335 ចំនួនមួយគ្រឿង។
ឈ.កុំព្យូទ័រយួរដៃម៉ាក ASUS ពណ៌ខ្មៅ មួយគ្រឿង។
ញ. កាបូបដៃចាស់ៗ ០២។
ដ.លោហធាតុពណ៌សមួយចំនួន (ខ្សែក ក្រវិល....)។
ឋ.ឯកសារមួយចំនួន។
ឌ.ឧបករណ៍អេឡិចត្រូនិចពណ៌ខ្មៅ ចំនួន ០២គ្រឿង។
ឍ.កុំព្យូទ័រយួរដៃម៉ាក La Vie ពណ៌ស មួយគ្រឿង។
ណ.ឧបករណ៍សម្រាប់សាកថ្មមួយចំនួន។
ត.ឧបករណ៍ម៉ាក hard drive by HITACHI ចំនួន ០១គ្រឿង។
ថ.នាឡិកាដៃចំនួន ០៦គ្រឿង។
ទ.ប្រាក់ដុល្លាអាមេរិកចំនួន ៤៦១$ (បួនរយហុកសិបមួយដុល្លាអាមេរិក)។
ធ.កាបូបស្ពាយសម្រាប់ដាក់កុំព្យូទ័រយួរដៃ ០១។
ន.វ៉ាលីដាក់ខោអាវ ០២។
ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ ចំពោះមុខជនជាប់ចោទឈ្មោះ NWOKO [redacted] ជនជាប់ចោទឈ្មោះ [redacted], ជនជាប់ចោទឈ្មោះ [redacted], កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ហៅ NTO និងជនជាប់ចោទឈ្មោះ [redacted] បើកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា: | ហត្ថលេខា: | ហត្ថលេខា: | ហត្ថលេខា និងត្រា: |
| [redacted] | [redacted] | [redacted] | [redacted] |

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤
ក្រឡាបញ្ជី
[redacted]